00196716

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

No. C22/I/40

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨

---

សេចក្តីសម្រេចលើសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំសេវាបកប្រែ

---

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky

**ជនត្រូវចោទ**

អៀង សារី

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 06 / 2008
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

១- **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)** បានទទួលសំណើពីសហមេធាវីបរទេសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានដាក់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ដើម្បីស្នើសុំការផ្ដល់សេវាបកប្រែ (“សំណើ”) ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនជនត្រូវចោទ **អៀង សារី** បណ្ដោះអាសន្ន។

២- យោងតាមវិធាន ២៣ (៧) និងវិធាន ៣០ នៃវិធានផ្ទៃក្នុង សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានអ្នកបកប្រែ ដើម្បីជួយសម្រួលដល់ទំនាក់ទំនងរវាងពួកគេ និង សហមេធាវីអន្តរជាតិ ក្នុងគោលបំណងធានាដល់ការតំណាងផ្លូវច្បាប់ឱ្យមានប្រសិទ្ធិភាព។

៣- សំណើនេះត្រូវបានរៀបចំឡើងក្នុងន័យទូទៅ ហើយពុំបានយោងទៅនឹងតម្រូវការចាំបាច់នូវការបកប្រែជាពិសេសណាមួយពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដែលពុំទាន់បានបំពេញនោះឡើយ។ ម្យ៉ាងវិញទៀត សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពុំបានចង្អុលបង្ហាញថាតើខ្លួនបានព្យាយាមធ្វើសំណើនេះតាមរយៈផ្នែករដ្ឋបាលរបស់ អ.វ.ត.ក ដើម្បីទទួលបានជំនួយបកប្រែភាសាហើយឬនៅ និងថាតើហេតុអ្វីបានជាអង្គបុរេជំនុំជម្រះត្រូវបានចាត់ទុកថាជាស្ថាប័នមួយសមស្របរបស់អ.វ.ត.ក ក្នុងការដោះស្រាយបញ្ហានេះដែរឬទេ។

៤- វិធានផ្ទៃក្នុងពុំបានចែងអំពីសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការបង្គាប់ឱ្យមានការផ្ដល់ជំនួយបកប្រែភាសា ក្នុងរូបភាពទូទៅដូចដែលបានស្នើសុំនោះឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

*ប្រកាសមិនទទួលយកសំណើនេះ។*

ភ្នំពេញ, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន**